Language: ភាសាខ្មែរ (កម្ពុជា)

# ពាក្យសុំថវិកាជំនួយខ្នាតតូចនៃកម្មវិធីជួយអាជីវកម្ម Business Navigators

សាលាក្រុងឡុងប៊ិច កំពុងផ្តល់ថវិកាជំនួយខ្នាតតូច តាមរយៈកម្មវិធីជួយអាជីវកម្ម Business Navigators ដើម្បីទ្រទ្រង់ការបើកមុខរបរ និងសហគ្រិនខ្នាតតូច ដោយផ្តល់ជាទុនខ្នាតតូច (២,៥00 ដុល្លារ ឬ ៥,000 ដុល្លារ)។ ថវិកាជំនួយនេះ គឺដើម្បីបើក ឬជួយអាជីវកម្មរបស់ពួកគាត់ឲ្យរីកលូតលាស់។ សហគ្រិនគួរប្រាស្រ័យទាក់ទងការងារជាមួយមន្ត្រីនៃកម្មវិធីជួយអាជីវកម្ម Inclusive Business Navigators របស់យើង ដើម្បីបំពេញផែនការអាជីវកម្មជាមូលដ្ឋានរបស់ខ្លួន និងផែនការដើម្បីយកថវិកាជំនួយទៅវិនិយោគ ក្នុងមុខរបរខ្នាតតូចថ្មីរបស់ខ្លួន។ រាល់អាជីវកម្មដែលចាប់អារម្មណ៍កម្មវិធីនេះ នឹងទទួលបានជំនួយបច្ចេកទេស និងសេវាជួយបង្ហាត់បង្ហាញ/ប្រឹក្សាយោបល់ ដើម្បីជួយឲ្យពួកកាត់បំពេញពាក្យសុំថវិកាជំនួយនេះឲ្យបានចប់សព្វគ្រប់។ សូមទាក់ទងផ្នែកជំនួយអាជីវកម្ម BizCare តាមលេខនេះ៖ 562-570-4249 ដើម្បីយើងខ្ញុំជួយភ្ជាប់ទៅរកជំនួយនោះ ឬ 4Biz@longbeach.gov ឬជួបខាងជំនួយអាជីវកម្ម Business Navigators នោះដោយផ្ទាល់តាម www.longbeach.gov/biznavigators ដើម្បីបានគេជួយរៀបចំពាក្យសុំនេះ។

លោកអ្នកអាចទាញយកពាក្យសុំនោះទាំងស្រុង ដើម្បីត្រៀមរៀបចំឆ្លើយតបទៅនឹងសំណួរមួយចំនួន មុនបំពេញពាក្យសុំនេះ៖ ពាក្យសុំនេះ មានជាភាសាអង់គ្លេស អេស្ប៉ាញ ខ្មែរ និងតាហ្គាឡុក។

សូមផ្ទៀតផ្ទាត់ជាមុនសិន ថាតើលោកអ្នកបានបំពេញគ្រប់លក្ខខណ្ឌដើម្បីដាក់ពាក្យនេះឬទេ មុននឹងដាក់ពាក្យសុំ។

ការបំពេញគ្រប់លក្ខខណ្ឌ៖

- ត្រូវតែមានទីតាំង និងបើកដំណោះរការនៅក្នុងដែនដីនៃទីក្រុងឡុងប៊ិច រដ្ឋកាលីហ្វ័រញ៉ា។
- ត្រូវតែជាអាជីវកម្មដែលទើបបើកដំបូង (បើកបានក្រោមពីរឆ្នាំ) ឬជាមុខរបរខ្នាតតូច (មានបុគ្គលិកពេញម៉ោងមិនលើសពីពីរនាក់ បូកទាំងម្ចាស់អាជីវកម្ម និងប្រាក់ចំណូលប្រចាំឆ្នាំ មិនត្រូវលើសពី ១៥0,000 ដុល្លារ)។
- ត្រូវតែជាមុខរបរឯកជនដើម្បីរកប្រាក់ចំណេញ រួមទាំងប្រភេទអាជីវកម្មឯកបុគ្គល ឬ អង្គការមិនរកប្រាក់កម្រៃ 501(c)3។
- ត្រូវតែមានអាជ្ញាប័ណ្ណអាជីវកម្មនៅទីក្រុងឡុងប៊ិច ឬកំពុងរត់ការសុំអាជ្ញាប័ណ្ណនេះ។
- ត្រូវតែជាមុខរបរដែលកំពុងបើកដំណើរការ និងសកម្ម។
- ត្រូវតែជាមុខរបរដែលមានម្ចាស់ឯករាជ្យ និងដំណើរការដោយឯករាជ្យ ដែលមិនមែនជាមុខរបរដែលបើកដើម្បីលក់មុខរបរនោះ (សាខាអាជីវកម្ម មិនត្រូវលក្ខខណ្ឌនេះទេ)។
- ក្រុមហ៊ុនសាជីវកម្ម ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនដៃគូមានកម្រិត ត្រូវមានអាជ្ញាប័ណ្ណ “មានសុពលភាព” នៅលេខាធិការរដ្ឋកាលីហ្វ័រញ៉ា។

* Required

## ផ្នែកកៈ ព័ត៌មានទំនាក់ទំនងអាជីវកម្ម

សូមប្រាប់ឈ្មោះរបស់អ្នក និងវិធីដែលយើងអាចទាក់ទងអ្នកបាន។

1. នាម *

2. ត្រកូល *

3. តើអ្នកត្រូវជាយ៉ាងម៉េចនឹងអាជីវកម្មដែលកំពុងដាក់ពាក្យសុំនេះ? *

- ◯ ខ្ញុំជួយបំពេញពាក្យសុំនេះឲ្យអាជីវកម្ម (និយោជិត, CPA, ដទៃទៀត)
- ◯ ខ្ញុំជាម្ចាស់អាជីវកម្ម

4. អ៊ីម៉េល *

5. លេខទូរស័ព្ទ *

6. ឈ្មោះអាជីវកម្ម *

7. DBA បើមាន

8. តើលោកអ្នកមានអាជ្ញាប័ណ្ណអាជីវកម្មនៅក្រុងឡុងប៊ិចឬទេ? *

- បាទ/ចាស
- ខ្ញុំបានដាក់ពាក្យសុំរួចហើយ ប៉ុន្តែនៅមិនទាន់បានវា។
- ខ្ញុំអត់ទាន់បានដាក់ពាក្យសុំអាជ្ញាប័ណ្ណនៅឡើយ។

9. សូមផ្តល់លេខអាជ្ញាប័ណ្ណអាជីវកម្មនោះ បើលោកអ្នកមានលេខនោះ។

10. ដើម្បីបំពេញគ្រប់លក្ខខណ្ឌ សម្រាប់ថវិកាជំនួយខ្នាតតូចនេះ គឺទាល់តែលោកអ្នកមានអាជ្ញាប័ណ្ណ ឬកំពុងរត់ការសុំអាជ្ញាប័ណ្ណនេះ។ ក្រុមជួយអាជីវកម្ម BizCare រង់ចាំជួយលោកអ្នកជានិច្ច បើលោកអ្នកត្រូវការឲ្យយើងខ្ញុំជួយ ដោយទូរស័ព្ទទៅលេខ 562-570-4249។ តើលោកអ្នកនឹងដាក់ពាក្យសុំអាជ្ញាប័ណ្ណអាជីវកម្មថ្ងៃនេះឬ?

ពាក្យសុំអាជ្ញាប័ណ្ណអាជីវកម្ម មាននៅតាមអនឡាញនៅទីនេះ៖ https://www.longbeach.gov/finance/business-info/business-licenses/apply-for-a-business-license/

- បាទ/ចាស ខ្ញុំនឹងដាក់ពាក្យសុំអាជ្ញាប័ណ្ណអាជីវកម្មថ្ងៃនេះ។
- ទេ! ខ្ញុំអត់បានគ្រោងនឹងដាក់ពាក្យសុំវានោះទេ។

11. គេហទំព័ររបស់អាជីវកម្ម *

12. អាសយដ្ឋានអាជីវកម្ម *

13. លេខអគារអាជីវកម្ម #

14. ស៊ីបកូដ *

15. តើអាជីវកម្មអ្នកចាប់បើកដំណើរការនៅឡូងប៊ិចចាប់តាំងពីពេលណា? *

MM/YYYY

16. សូមជ្រើសយកប្រភេទអាជីវកម្មដែលអ្នកបើកដំណើរការ៖ *

- ◯ ឯកត្តបុគ្គល
- ◯ ដៃគូ
- ◯ ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត
- ◯ សាជីវកម្ម (S Corp, C Corp, ។ល។)
- ◯ អ្នកម៉ៅការឯករាជ្យ
- ◯ អង្គការមិនរកប្រាក់កម្រៃ 501(c)3

17. សូមរៀបរាប់អំពីអាជីវកម្មអ្នក។ (ឧទាហរណ៍ រៀបរាប់អំពីផលិតផលសំខាន់ក្នុងហាង និងសេវា និងព័ត៌មានពិស្តារសំខាន់ៗផ្សេងទៀត សម្រាប់ឲ្យយើងខ្ញុំយល់ដឹងអំពីលក្ខណៈនៃអាជីវកម្មអ្នក។ (សូមឆ្លើយខ្លីៗ) *

18. តើអាជីវកម្មនេះមានបុគ្គលិកពេញម៉ោងប៉ុន្មានអ្នក (តិចបំផុតម្នាក់ៗធ្វើការ ៣៥ ម៉ោងក្នុងមួយសប្តាហ៍) រួមទាំងខ្លួនអ្នក? *

- ◯ 0
- ◯ ១
- ◯ ២
- ◯ ៣-៥
- ◯ លើសពី ៥

19. សូមជ្រើសយកចម្លើយមួយ ដែលរៀបរាប់ត្រូវនឹងទីតាំងអាជីវកម្មអ្នកៈ *

- ខ្ញុំជាម្ចាស់កម្មសិទ្ធិកន្លែងរកស៊ីនេះ
- ខ្ញុំជួលពីគេ
- ខ្ញុំបើកហាងនៅផ្ទះខ្ញុំ
- ខ្ញុំបើកហាងចល័ត (ឧទាហរណ៍ លក់ដូរតាមដងផ្លូវ លក់ចំណីអាហារតាមរថយន្ត ។ល។)

20. តើអាជីវកម្មនេះបើកទទួលសាធារណជនទូទៅ? *

- បាទ/ចាស
- ទេ

21. តើអាជីវកម្មនេះជាផ្នែកមួយនៃសាខាជាតិ? *

- បាទ/ចាស
- ទេ

22. សូមជ្រើសយកប្រាក់ចំណូលសរុប ដែលអាជីវកម្មអ្នករកបាន ក្នុងរយៈពេល ១២ ខែ កន្លងទៅ ដែលអ្នកបានប្រកាសពន្ធ (២០២២ ឬ ២០២៣) *

- ◯ តិចជាង $10,000
- ◯ $10,001 ដល់ $50,000
- ◯ $100,001 ដល់ $150,000
- ◯ $500,001 ដល់ $500,000
- ◯ លើស $500,000
- ◯ អង្គការខ្ញុំមិនទាន់បង្កើត ឬរាយការណ៍ប្រាក់ចំណូល កាលពីឆ្នាំ ២០២២ ឬ ២០២៣ ទេ។

23. តើអ្នកកំពុងជាប់បញ្ហាបំពានកូដ លិខិតអនុញ្ញាតសុខភាព ឬការបំពានបទបញ្ជាសុខភាព ជំងឺកូវីដ-១៩ ឬទេ? *

- ◯ បាទ/ចាស
- ◯ ទេ
- ◯ ខ្ញុំអត់ដឹងទេ

## ផ្នែកខ៖ ផែនការអាជីវកម្ម

24. តើបញ្ហាអ្វីខ្លះ ដែលអាជីវកម្មរបស់លោកអ្នកដោះស្រាយ /តើបញ្ហាធំៗជាងគេចំនួនបី ដែលអតិថិជនរបស់លោកអ្នកកំពុងជួបប្រទះ មានអ្វីខ្លះ? ចូររៀបរាប់ជាចំណុចៗ បើធ្វើដូច្នេះងាយជាង។ *

ឧទាហរណ៍៖ អ្នកដែលរវល់ខ្លាំង មិនអាចរកអាហារស្រស់ៗ និងចម្អិនតាមផ្ទះបាន។

25. តើបញ្ហាទាំងនេះ កំពុងត្រូវដោះស្រាយដោយរបៀបណា? *

សំណូមពរ៖ សូមរកមើលបញ្ហារួម ដែលបានវេទិកាជជែកគ្នា ឬពីកន្លែងដែលអតិថិជនបញ្ចេញមតិ ពាក់ព័ន្ធនឹងឧស្សាហកម្មរបស់លោកអ្នក។ ចូរកំណត់ភាពចន្លោះប្រហោង ដែលមានក្នុងដំណោះស្រាយបច្ចុប្បន្ន។ រៀបចំធ្វើការស្ទង់មតិក្នុងសហគមន៍របស់លោកអ្នក។ ចូលរួមកិច្ចប្រជុំនៅមូលដ្ឋាន ឬកម្មវិធីផ្សេងៗ ដើម្បីស្រង់មតិ។

26. តើនរណាខ្លះជាអតិថិជន ឬអ្នកប្រើប្រាស់សេវាជាគោលដៅ? *

ឧទាហរណ៍៖ គ្រួសារដែលជាប់រវល់ និងអ្នករបរអាជីព ដែលរកមើលជម្រើសទិញអាហារដែលចម្អិតតាមផ្ទះ និងងាយៗ។

27. តើអតិថិជនរបស់លោកអ្នក មានលក្ខណៈបែបណាខ្លះ? *

ឧទាហរណ៍៖ ពលរដ្ឋនៅក្រុង ឬសហគមន៍តូច អ្នកមកដើរផ្សារកសិករ ឬការតាំងពិព័រណ៍សិប្បកម្ម។

28. តើមានផ្នែកទីផ្សារជាក់លាក់ណាមួយ ឬទីតាំងអតិថិជន ដែលអ្នកចង់បាន? *

29. តើអ្វីខ្លះដែលធ្វើឲ្យអាជីវកម្មរបស់លោកអ្នក មានលក្ខណៈពិសេសខុសពីអ្នកដទៃ? *

ឧទាហរណ៍៖ "នាំចម្ការមកដល់មុខផ្ទះរបស់លោកអ្នក ដោយផ្តល់ជូនផលិតផលដាំក្នុងមូលដ្ឋាន ជាផលិតផលសរីរាង្គ និងមានតម្លៃសមរម្យ"។

30. តើអ្វីខ្លះដែលធ្វើឲ្យដំណោះស្រាយរបស់លោកអ្នក មានភាពប្លែក ឬល្អប្រសើរជាងដំណោះស្រាយដែលមានស្រាប់? *

សំណូមពរ៖ ផ្តោតលើការទាក់ទាញទឹកចិត្តអតិថិជន អត្ថប្រយោជន៍សម្រាប់សហគមន៍ ឬស្នាដៃសិប្បកម្មពិសេសនៃផលិតផល/សេវារបស់លោកអ្នក។

31. តើអ្វីខ្លះជាជម្រើសសំខាន់ជាងគេចំនួនបីនៃដំណោះស្រាយរបស់លោកអ្នក? *

ឧទាហរណ៍៖ សេវាដឹកជញ្ជូនផលិតផលសរីរាង្គដល់ផ្ទះ វត្ថុអនុស្សាវរីយ៍ធ្វើដោយដៃដែលសម្រិតសម្រាំងពីសិប្បករនៅមូលដ្ឋាន គំនូរសិល្បៈតាមអនឡាញ ដែលជាស្នាដៃវិចិត្រករនៅមូលដ្ឋាន ដែលអតិថិជនអាចមកមើលដល់បន្ទប់ស្ទូឌីយ៉ូបាន។

32. តើដំណោះស្រាយរបស់លោកអ្នក អាចដោះស្រាយបញ្ហាទាំងនោះ បានដោយរបៀបណា? *

33. ចូររៀបរាប់មធ្យោបាយសម្រាប់លក់ផលិតផលរបស់អាជីវកម្មលោកអ្នក៖ *

ឧទាហរណ៍៖ ការលក់ផ្ទាល់តាមគេហទំព័រ ចាប់ដៃគូគ្នាជាមួយអ្នកល្បីៗក្នុងឧស្សាហកម្មនេះ លក់អនឡាញតាមរយៈការបង្កើតមាតិការ និងផ្សាយតាមប្លក់ ប្រព័ន្ធផ្សព្វផ្សាយសង្គម លក់តាមហាងដោយអតិថិជនមកទិញដោយផ្ទាល់ ដាក់តាំងលក់តាមមុខហាងក្នុងរង្វង់ ២ ម៉ែយ៍ ។ល។

34. ចូររៀបរាប់លំហូរប្រាក់ចំណូលពីអាជីវកម្មរបស់លោកអ្នក ឲ្យបាន ២-៥ មុខ៖ *

ឧទាហរណ៍៖ ការចុះឈ្មោះជាវសេវាជាប្រចាំ លក់ផលិតផលលាងឃ្លាំង ប្រាក់កម្រៃជើងសា

35. ចូររៀបរាប់ការចំណាយដើម្បីដំណើរការអាជីវកម្មរបស់លោកអ្នក៖ *

ឧទាហរណ៍៖ ការចំណាយលើការបង្កើតកម្មវិធី app; ការចំណាយលើផ្នែកទីផ្សារ និងផ្សាយពាណិជ្ជកម្ម ប្រាក់ខែបុគ្គលិក។

36. ចូររៀបរាប់យ៉ាងតិចឲ្យបានបីចំណុច អំពីតួលេខសំខាន់ៗ ដែលបញ្ជាក់ថាអាជីវកម្មរបស់លោកអ្នកដំណើរការដោយរបៀបណា។ ចូរបញ្ជាក់បើលោកអ្នកមានតួលេខជាគោលដៅ ដែលត្រូវសម្រេចឲ្យបានណាមួយ។ ប៉ុន្តែ ក៏មិនអីដែរ បើលោកអ្នកអត់ទាន់មានវា។ *

ឧទាហរណ៍៖ ប្រាក់ចំណូល ចំនួនអតិថិជន ។ល។

## ផ្នែកគ៖ ផែនការអាជីវកម្ម

37. តើលោកអ្នកនឹងយកប្រាក់ជំនួយនោះទៅធ្វើអ្វីខ្លះ? *

- [ ] កែលម្អឧបករណ៍
- [ ] កែលម្អបច្ចេកវិទ្យា
- [ ] បណ្តុះបណ្តាលបុគ្គលិក/រក្សាទុកបុគ្គលិក
- [ ] កែលម្អអគារ
- [ ] រកទីផ្សារ

38. តើលោកអ្នកនឹងវិនិយោគប្រាក់ជំនួយនេះ ដោយរបៀបណា ទៅលើអាជីវកម្មនោះ? សូមរៀបរាប់អំពីផែនការរបស់លោកអ្នក ក្នុងការប្រើប្រាស់មូលនិធិនេះ សម្រាប់តម្លៃដែលអាចប៉ាន់ស្មានណាមួយ៖ *

39. តើលោកអ្នកស្នើសុំថវិកាជំនួយទំហំប៉ុនណា សម្រាប់អាជីវកម្មរបស់លោកអ្នក? *

- ◯ $2,500
- ◯ $5,000

40. តើលទ្ធផលវិជ្ជមានអ្វីខ្លះ ដែលលោកអ្នកគិតថា ថវិកាជំនួយនេះនឹងមានចំពោះអាជីវកម្មនេះ? *

## ផ្នែកឃ៖ ប្រជាសាស្រ្ត

ទិន្នន័យនេះនឹងមិនយកទៅប្រើប្រាស់ ក្នុងការវាយតម្លៃអំពីពាក្យសុំនោះឡើយ។ យើងប្រើសម្រាប់គោលបំណងយល់ដឹងអំពីស្ថានភាពប្រជាសាស្រ្តនៅក្នុងកម្មវិធីនេះ និងដើម្បីយើងខ្ញុំអាចផ្តល់សេវាជូនពលរដ្ឋឲ្យបានទូលំទូលាយ។

41. សូមជ្រើសយកចម្លើយណាមួយ ឬទាំងអស់នៅខាងក្រោម ដែលសមស្របទៅតាមលក្ខណៈអាជីវកម្មអ្នក។ ពាក្យថាកម្មសិទ្ធិភាពភាគច្រើន គឺមានន័យថា សិទ្ធិគ្រប់គ្រងលើសពី ៥0%។

- ☐ ភាគច្រើនគ្រប់គ្រងដោយជនជាតិក្រៅពីស្បែកស
- ☐ ភាគច្រើនគ្រប់គ្រងដោយជនជាតិស្បែកស
- ☐ ភាគច្រើនគ្រប់គ្រងដោយស្ត្រី
- ☐ សុំមិនឆ្លើយ

42. តើភាសាអ្វីអ្នកនិយាយញឹកញាប់ជាងគេនៅផ្ទះ?

- ○ អង់គ្លេស
- ○ អេស្ប៉ាញ
- ○ តាហ្គាឡុក
- ○ ខ្មែរ

43. ខ្ញុំកំណត់អត្តសញ្ញាខ្ញុំថាជា (សូមជ្រើសយកចម្លើយទាំងអស់ដែលសមស្រប)៖

- ☐ អាស៊ី/អ្នកដែនកោះប៉ាស៊ីហ្វិក
- ☐ ស្បែកខ្មៅ/ជនជាតិអាមេរិកដើមកំណើតអាហ្វ្រិក
- ☐ ស្បែកស
- ☐ អេស្ប៉ានិក
- ☐ មជ្ឈិមបូព៌ា/អាហ្វ្រិកខាងជើង
- ☐ ជនជាតិអាមេរិកដើម/ជនជាតិដើម
- ☐ សុំមិនឆ្លើយ

44. ភេទពីកំណើត៖

- ○ ស្រី
- ○ ប្រុស
- ○ មិនកំណត់ភេទណាមួយ
- ○ សុំមិនឆ្លើយ

This content is neither created nor endorsed by Microsoft. The data you submit will be sent to the form owner.

Microsoft Forms

## ផ្នែក Z៖ ការប្រកាសអះអាងបស់សាមីខ្លួន

45. តទៅនេះ ខ្ញុំសូមប្រកាស និងព្រមព្រៀងថា ខ្ញុំត្រូវបានប្រគល់សិទ្ធិអនុញ្ញាតឲ្យដាក់ពាក្យសុំនេះ ក្នុងនាមជាម្ចាស់អាជីវកម្ម និង/ឬ ដាក់ជំនួសអង្គភាពអាជីវកម្ម ដែលមានអាជ្ញាប័ណ្ណអាជីវកម្មនៅក្នុងក្រុងឡុងប៊ិច។

ខ្ញុំទទួលស្គាល់ និងព្រមព្រៀងថាពាក្យសុំ ការធ្វើជាតំណាង ឬសេចក្តីថ្លែងការណ៍ណាមួយ ដែលធ្វើឡើងដោយភ្នាក់ងារណាមួយ ឬបុគ្គលិកណាម្នាក់របស់សាលាក្រុង ដែលមិនមានក្នុងពាក្យយសុំនេះ នឹងត្រូវចាត់ទុកជាមោឃៈ និងមិនអាចយកជាការបាន ហើយថាខ្ញុំមិនពឹងលើការសន្យា ការធ្វើជាតំណាង ឬសេចក្តីថ្លែងការណ៍នោះឡើយ។

ខ្ញុំទទួលស្គាល់ និងព្រមព្រៀងថាពាក្យសុំនេះ នឹងត្រូវត្រួតពិនិត្យរកមើលការបំពេញលក្ខខណ្ឌគ្រប់គ្រាន់ សម្រាប់ចូលរួមកម្មវិធីនេះ និងថាពាក្យសុំនេះអាចត្រូវបដិសេធ បើអាជីវកម្មខ្ញុំត្រូវបានរកឃើញថាមិនគ្រប់លក្ខខណ្ឌសម្រាប់ទទួលបានថវិកាជំនួយ ឬបើថវិកាជំនួយដែលមាននោះ ឥឡូវបានអស់ទៅហើយ។

ខ្ញុំទទួលស្គាល់ និងព្រមព្រៀងថាពាក្យសុំនេះ មិនមានន័យថាជាការទទួលបានសិទ្ធិ ឬជាសិទ្ធិក្នុងការទទួលបានថវិកាជំនួយនោះឡើយ។

ខ្ញុំទទួលស្គាល់ និងព្រមព្រៀងថា ខ្ញុំបានអានការទទួលស្គាល់នេះ និងដំបូន្មាន និងថាខ្ញុំដឹង និងស្ម័គ្រចិត្តដាក់ពាក្យសុំនេះ ទៅតាមការទទួលស្គាល់ និងដំបូន្មាននេះ។

អាស្រ័យហេតុនេះ ខ្ញុំសូមប្រកាស និងព្រមព្រៀងថា ព័ត៌មានដែលមាននៅក្នុងពាក្យសុំនេះ និងឯកសារភ្ជាប់មកជាមួយពាក្យសុំនេះ គឺពេញលេញ ពិត និងត្រឹមត្រូវ។ ខ្ញុំដឹងថាការក្លែង, ផ្តល់ព័ត៌មានមិនពិត ឬសេចក្តីថ្លែងការណ៍បោកបន្លំនៃអង្គហេតុណាមួយ គឺជាដើមហេតុនៃការបដិសេធពាក្យសុំនេះ និងអាចប៉ះពាល់ដល់ថវិកាជំនួយដទៃទៀតទៅថ្ងៃមុខ ដែលផ្តល់ជូនដោយសាលាក្រុង ដោយសាលាក្រុងរក្សាសិទ្ធិក្នុងការចាត់ការតាមផ្លូវច្បាប់ ដើម្បីជួសជុលការខូចខាតពីការបោកបន្លំនេះ។

ខ្ញុំយល់ព្រមឲ្យសាលាក្រុងឡុងប៊ិច ឬមន្ត្រីចាត់តាំងរបស់ខ្លួន ដើម្បីទាក់ទងខ្ញុំ ដើម្បីសុំទិន្នន័យ ឬព័ត៌មានពាក់ព័ន្ធឯទៀត សម្រាប់គោលបំណងនៃការអនុវត្តតាមការបំពេញលក្ខខណ្ឌនៃកម្មវិធីនេះ។

ខ្ញុំសូមប្រកាសនៅចំពោះមុខច្បាប់នៃការដាក់ទោសទណ្ឌចំពោះការក្លែងបន្លំ ថារាល់ព័ត៌មានដែលផ្តល់ជូននៅក្នុងពាក្យសុំនេះ និងផ្តល់ជូនជាឯកសារដាក់មកជាមួយទាំងអស់ គឺពិត និងត្រឹមត្រូវ។

ការចុចយក “ខ្ញុំយល់ព្រម”នេះ គឺខ្ញុំចុះហត្ថលេខាលើពាក្យសុំនេះតាមប្រព័ន្ធអេឡិចត្រូនិក។ ខ្ញុំព្រមព្រៀងថា ហត្ថលេខាអេឡិចត្រូនិករបស់ខ្ញុំ គឺមានភាពស្របច្បាប់ស្មើនឹងហត្ថលេខាដែលចុះដោយផ្ទាល់ដែរ។ *

○ ខ្ញុំយល់ព្រម